បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល ថ្ងៃទី០៩ ខែ៦ ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៨០
ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១
សាលក្រមលេខ៖ ០២ (ផ.វ.ន)
ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាលនាថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ៩ ព្រឹកដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៨០ អក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ដែលមានជនជាប់ចោទ៖

ឈ្មោះ: [redacted] សុផល ភេទប្រុស អាយុ៥៨ ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិថ្មី ឃុំថ្មី ស្រុកកំពង់រោ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅភូមិព្រៃកល្វា ឃុំព្រៃគគីរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ: [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ: [redacted] (រ) មានកូនចំនួន ០២ នាក់។

ត្រូវបានជាប់ចោទពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិព្រៃកល្វា ឃុំព្រៃគគីរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីខែសីហា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

មេធាវីការពារជនជាប់ចោទឈ្មោះ: [redacted] ម៉េងអ៊ាម។

Scanned by CamScanner

<u>**ដំណើរអង្គហេតុមានដូចតទៅ**</u>

កាលពីខែសីហា ឆ្នាំ២០១០ វេលាម៉ោង ១៧ និង០០នាទី ជនរងគ្រោះឈ្មោះ [redacted] វិមាន ភេទស្រី អាយុ ៩ឆ្នាំ កំពុងដេកនៅលើផ្ទះ ស្ថិតនៅភូមិល្វា ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ជាមួយជនត្រូវចោទឈ្មោះ [redacted] សុផល បន្ទាប់មកឈ្មោះ [redacted] សុផល បានមកដេកទ្រាបពីលើជនរងគ្រោះឈ្មោះ [redacted] វិមាន ហើយបានគំរាមនាងមិនឲ្យស្រែក និងបានចាប់ស្រាតខោរបស់នាង និងស្រាតខោខ្លួន នៅពេលនោះឈ្មោះ [redacted] សុផល បានបញ្ចេញប្រដាប់ភេទរបស់ខ្លួនបំរុងដាក់បញ្ចូលទៅក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ តែចៃដន្យឈ្មោះ [redacted] តី និងឈ្មោះ [redacted] សៀ បានឡើងមកទាន់ ភ្លាមនោះឈ្មោះ [redacted] សុផល បានរត់គេចខ្លួនតែម្តង។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ៦១៧ ដកសព ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ៖ ៤១៩ ចុះថ្ងៃទី០២ ខែ កញ្ញា ឆ្នាំ២០១៣។

បានឃើញ ចំណារចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣។

**នាពេលសវនាការ**

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] វិមាន បានឆ្លើយថា៖ ខ្លួនមិនបានចាំថ្ងៃខែឆ្នាំទេ វេលាម៉ោងប្រហែល ៥ ល្ងាច ខ្លួនកំពុងអង្គុយលើផ្ទះនៅក្នុងភូមិព្រៃកល្វា ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល តែម្នាក់ឯង ចំណែកម៉ីងខ្លួនឈ្មោះ តី គាត់កំពុងដេរខោអាវនៅក្រោមផ្ទះ បន្ទាប់មកឈ្មោះ ផល ត្រូវជាពូរបស់ខ្លួន បានដើរមករកខ្លួន ហើយគាត់បានឡើងទ្រាបពីលើខ្លួន ព្រមទាំងនិយាយថា បើខ្លួនហ៊ានស្រែក គាត់នឹងយកកាំបិតមកចាក់សម្លាប់ខ្លួន រួចគាត់បានស្រាតខោខ្លួនឯង និងស្រាតខោរបស់ខ្លួន គាត់បានយកប្រដាប់ភេទគាត់ដាក់លើប្រដាប់ភេទរបស់ខ្លួន ភ្លាមនោះម៉ីងខ្លួន ឈ្មោះ តី និងយាយឈ្មោះ [redacted] សៀ បានឡើងមកទាន់ ហើយឈ្មោះ ផល បានរត់ចុះទៅដីតែម្តង។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សៀ បានឆ្លើយថា៖ នៅថ្ងៃមិនចាំខែសីហា ក្នុងឆ្នាំ២០១០ នៅវេលាម៉ោង ១៦ និង០០នាទី ចៅស្រីខ្លួនឈ្មោះ [redacted] វិមាន បានទៅដេកលេងនៅលើផ្ទះរបស់ឈ្មោះ [redacted] សុផល រីឯខ្លួនបានដើរទៅផ្ទះឈ្មោះ រ៉ែន នៅខាងត្បូងផ្ទះឈ្មោះ [redacted] សុផល ប្រហែលជា ១៥០ ម៉ែត្រ លុះដល់ម៉ោង ១៧ និង០០នាទី ខ្លួនក៏បានដើរទៅផ្ទះឈ្មោះ [redacted] សុផល វិញ ហើយខ្លួន និងកូនស្រីខ្លួនឈ្មោះ [redacted] តី ត្រូវជាប្រពន្ធឈ្មោះ [redacted] សុផល បាននាំគ្នាដើរឡើងទៅលើផ្ទះ ដោយខ្លួនដើរពីក្រោយកូនស្រីខ្លួន ពេលឡើងទៅដល់ស្រាប់តែឃើញ ឈ្មោះ [redacted] សុផល កំពុងតែដេកផ្កាប់មុខទ្រាបពីលើចៅស្រីខ្លួនដោយដៃ [redacted] សុផល ម្ខាងចាប់ទាញស្រាតខោចៅស្រីរបស់ខ្លួនមកដល់ត្រឹមភ្លៅ ឯប្រដាប់ភេទរបស់ឈ្មោះ [redacted] សុផល បញ្ចេញមកក្រៅរៀបនឹងដាក់ចូលទៅក្នុងប្រដាប់ភេទចៅស្រីរបស់ខ្លួនទៅហើយ។ ពេលនោះខ្លួនមិនបានចាំថា ឈ្មោះ [redacted] សុផល ស្លៀកខោ ឬក្រម៉ាទេ លុះឃើញពួកខ្លួន ឈ្មោះ [redacted] សុផល ក៏ស្ទុះក្រោកចុះមកដីឯតទឹកទៅ រីឯចៅខ្លួនដេកផ្ងារមានសភាពស្លេកស្លាំង មិនហ៊ានស្រែកឡើយ ចាប់តាំងពីពេលនោះមកឈ្មោះ [redacted] សុផល ឧស្សាហ៍រករឿងឈ្លោះប្រកែកជាមួយខ្លួនណាស់ ព្រមកាន់កាំបិតគំរាមរកកាប់ខ្លួនទៀតផង

Scanned by CamScanner

ដោយខ្លួនខ្លាចឈ្មោះ [redacted] សុផល សម្លាប់ គឺមិនហ៊ានប្ដឹងទៅប៉ុស្ដិ៍នគរបាលនោះទេ គឺខ្លួនគ្រាន់តែនិយាយប្រាប់ឈ្មោះ ហេង ជាតំណាងឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ពោធិបូនប៉ុណ្ណោះ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] គឺ បានឆ្លើយថា៖ កាលពីថ្ងៃទីមិនចាំអំឡុងខែឧសភា ឆ្នាំ ២០១០ វេលាម៉ោងប្រហែល ២ រសៀល ខ្លួនរួមជាមួយក្មួយស្រីខ្លួនឈ្មោះ [redacted] វិមាន ហៅ ង៉ែត អាយុ ១០ ឆ្នាំ បាននាំគ្នាលាងចានបាយនៅក្រោមផ្ទះ ឯប្ដីខ្លួនឈ្មោះ [redacted] សុផល ងូតទឹករួចគាត់ឡើងទៅលើផ្ទះស្លៀកពាក់ខោអាវ បំរុងទៅភូមិខាងលើ ចំណែកម្ដាយខ្លួនឈ្មោះ [redacted] សៀ គាត់បានដើរទៅលេងនៅផ្ទះរបស់ឈ្មោះ រ៉ែន បាត់ហើយ បានបន្តិចក្មួយស្រីខ្លួនឈ្មោះ [redacted] វិមាន ក៏ឡើងទៅលើផ្ទះខ្លួនមិនដឹងថាឡើងទៅធ្វើអ្វីទេ បន្ទាប់មកខ្លួនក៏បានយកចានទៅទុក ពេលទៅដល់លើផ្ទះឃើញប្ដីខ្លួនអង្គុយនៅក្បែរទូរ ស្លៀកខោជើងវែង ពណ៌ប្រផេះ ពាក់អាវដៃវែង ពណ៌ស ឯក្មួយស្រីខ្លួនឈ្មោះ [redacted] វិមាន អង្គុយជិតចង្ក្រាន ចំងាយពីប្ដីខ្លួនប្រហែលជាងមួយម៉ែត្រ ឯកូនប្រុសខ្លួនឈ្មោះ [redacted] ណាង អាយុ ៥ឆ្នាំ កំពង់ដេកនៅខាងមុខទូរ ចំណែកម្ដាយខ្លួនគាត់មិនទាន់ត្រឡប់មកដល់ផ្ទះវិញទេ។ ភ្លាមនោះប្ដីខ្លួនក៏បាននាំក្មួយស្រីខ្លួនទៅងូតទឹក នៅពេលងូតទឹកឲ្យក្មួយស្រីខ្លួនរួច ប្ដីខ្លួនក៏ដើរទៅភូមិបាត់ទៅ រហូតដល់ម៉ោង ៥ ល្ងាច ទើបម្ដាយខ្លួនមកដល់ផ្ទះខ្លួនវិញ នៅពេលខ្លួនឡើងទៅលើផ្ទះនោះ ម្ដាយខ្លួនគាត់មិនទាន់មកដល់ គាត់មិនបានឡើងទៅលើផ្ទះជាមួយខ្លួនទេ។

-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការៈ ក្រោយពីបានស្ដាប់អំណានចម្លើយជនរងគ្រោះ និងអំណានចម្លើយសាក្សី តំណាងអយ្យការយល់ឃើញថា កាលពីខែសីហា ឆ្នាំ២០១០ ជនជាប់ចោទឈ្មោះ [redacted] សុផល ពិតជាបានជាបានស្រាតរោមជនរងគ្រោះ និងយកប្រដាប់ភេទបម្រុងដាក់បញ្ចូលប្រដាប់ភេទជនរងគ្រោះ ប៉ុន្តែឈ្មោះ [redacted] សៀ បានមកទាន់ ជនជាប់ចោទក៏បានបញ្ឈប់សកម្មភាពរបស់ខ្លួន ដែលអំពើនេះច្បាប់ចាត់ទុកថាជាបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះតំណាងអយ្យការសូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ៖ ៦១៧ដកសព ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ទុកជាបានការទាំងស្រុង។

-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទៈ ក្រោយពីបានស្ដាប់អំណានចម្លើយជនរងគ្រោះ និងអំណានចម្លើយសាក្សី ខ្លួនជាមេធាវីការពារឱ្យជនជាប់ចោទ ស្នើសុំដល់តុលាការមេត្តាពិចារណា និងសម្រេចតាមច្បាប់។

ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនរងគ្រោះ

ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្ដាប់សេក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

Scanned by CamScanner

## សាលាដំបូងខេត្តកណ្តាល
## យល់ឃើញថា

១.ជនរងគ្រោះឈ្មោះ [redacted] វិមាន បានឆ្លើយថា៖ ខ្លួនមិនបានចាំថ្ងៃខែឆ្នាំទេ វេលាម៉ោងប្រហែល ៥ ល្ងាច ខ្លួនកំពុងអង្គុយលើផ្ទះនៅក្នុងភូមិព្រែកល្វា ឃុំព្រែកតាគូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល តែម្នាក់ឯង បន្ទាប់មកឈ្មោះ ផល ត្រូវជាពូរបស់ខ្លួន បានដើរមករកខ្លួន ហើយគាត់បានឡើងទ្រោបពីលើខ្លួន ព្រមទាំងនិយាយថា បើខ្លួនហ៊ានស្រែក គាត់នឹងយកកាំបិតមកចាក់សម្លាប់ខ្លួន រួចគាត់បានស្រាតខោខ្លួនឯង និងស្រាតខោរបស់ខ្លួន គាត់បានយកប្រដាប់ភេទគាត់ដាក់លើប្រដាប់ភេទរបស់ខ្លួន ភ្លាមនោះពូខ្លួន ឈ្មោះ គី និងបងប្រុសឈ្មោះ [redacted] សៀ បានឡើងមកទាន់ ហើយឈ្មោះ ផល បានរត់ចុះទៅដីតែម្តង ដែលមានភាពស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយសាក្សីឈ្មោះ [redacted] សៀ។

២.សាក្សីឈ្មោះ [redacted] សៀ បានឆ្លើយថា៖ នៅថ្ងៃមិនចាំខែសីហា ក្នុងឆ្នាំ២០១០ នៅម៉ោង១៧ និង០០នាទី ខ្លួន និងកូនស្រីខ្លួនឈ្មោះ [redacted] គី ត្រូវជាប្រពន្ធឈ្មោះ [redacted] សុផល បាននាំគ្នាដើរឡើងទៅលើផ្ទះ ដោយខ្លួនដើរពីក្រោយកូនស្រីខ្លួន ពេលឡើងទៅដល់ស្រាប់តែឃើញ ឈ្មោះ [redacted] សុផល កំពុងតែដេកផ្កាប់មុខទ្រោបពីលើចៅស្រីខ្លួនដោយដៃ [redacted] សុផល ម្ខាងចាប់ទាញស្រាតខោចៅស្រីរបស់ខ្លួនមកដល់ត្រឹមភ្លៅ ឯប្រដាប់ភេទរបស់ឈ្មោះ [redacted] សុផល បញ្ចេញមកក្រៅរៀបនឹងដាក់ចូលទៅក្នុងប្រដាប់ភេទចៅស្រីរបស់ខ្លួនទៅហើយ។

៣.តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] វិមាន និងសាក្សីឈ្មោះ [redacted] សៀ អាចបញ្ជាក់បានថា កាលពីខែសីហា ឆ្នាំ២០១០ ជនជាប់ចោទឈ្មោះ [redacted] សុផល ពិតជាបានធ្វើសកម្មភាពចាប់ស្រាតខោជនរងគ្រោះ និងខោខ្លួនក្នុងគោលបំណងដាក់បញ្ចូលលិង្គរបស់ខ្លួន ចូលក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ ប៉ុន្តែចៃដន្យឈ្មោះ [redacted] សៀ បានមកទាន់ ធ្វើឱ្យជនជាប់ចោទបញ្ឈប់សកម្មភាពរបស់ខ្លួន ដែលអំពើនេះច្បាប់ចាត់ទុកជាបទៈ **ប៉ុនប៉ងរំលោភសេពសន្ថវៈ**។

៤.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល ប្រព្រឹត្តលើជនរងគ្រោះជាអនីតិជនដែលមានអាយុទើបតែ ០៩ ឆ្នាំ ដែលជាបុគ្គលមានភាពទន់ខ្សោយពិសេស ដោយមូលហេតុនៃអាយុបុគ្គល ហេតុដូច្នេះតុលាការធ្វើការកែប្រែបទចោទប្រកាន់លើជនជាប់ចោទពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ** មកបទៈ **ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ**។

៥.អំពើរបស់ជនត្រូវចោទឈ្មោះ [redacted] សុផល ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសង្គម កិត្តិយស និងរូបកាយរបស់ជនរងគ្រោះ ហើយជនត្រូវចោទជានីតិជន មានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។

Scanned by CamScanner

៦.មានភស្តុតាង និងកត្តាគ្រប់គ្រាន់លើឈ្មោះ [redacted] សុផល ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ ពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) ប្រព្រឹត្តនៅភូមិព្រៃកល្វា ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពី ខែសីហា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

៧.ជនជាប់ចោទឈ្មោះ [redacted] សុផល ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ បានរត់គេចខ្លួន ហើយអំពើរបស់ជនជាប់ចោទត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពីមួយឆ្នាំ គប្បីសាលាដំបូងខេត្តកណ្តាលចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទ [redacted] សុផល ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេចសេចក្តី**

១/កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ៥៨ឆ្នាំ ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ មកបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

២/ផ្តន្ទាទោសៈ ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ៥៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ៧ ឆ្នាំ (ប្រាំពីរឆ្នាំ) ពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) ប្រព្រឹត្តនៅភូមិព្រៃកល្វា ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីខែសីហា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

៣/ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ៥៨ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ កំបាំងមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមក្រុមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] [redacted] | [redacted] |

**បានឃើញ**

**ចៅក្រម**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កណ្តាល, ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤

**ក្រឡាបញ្ជីសវនាការ**

[redacted]

Scanned by CamScanner